ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ១៥៦ ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥

# ប្រកាស
# ស្តីពី
# ការបង្កើតលេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាល

---

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១៥ និងលេខ នស/រកត/០៣០៥/១១៦ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការតែងតាំងមេធាវីរាជរដ្ឋាភិបាល

-យោងតាមការងារចាំបាច់

## សម្រេច

**ប្រការ ១** : ត្រូវបានបង្កើតលេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាល ជាសេនាធិការឱ្យមេធាវីរាជរដ្ឋាភិបាល និងមានទីតាំង នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ២ :** លេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាល ដឹកនាំដោយនាយលេខាធិការដ្ឋាន ០១ រូប អមដោយនាយរងលេខាធិការដ្ឋានមួយចំនួន ជាជំនួយការ ។

លេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាលមានការិយាល័យទទួលពាក្យបណ្តឹង និងការិយាល័យស្រាវជ្រាវ ព្រមទាំងមានមន្ត្រីមួយចំនួនសម្រាប់បម្រើការ ។

**ប្រការ ៣ :** លេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាល មានភារកិច្ច :

-ទទួល និងពិនិត្យ ស្រាវជ្រាវ លើរាល់ពាក្យបណ្តឹងសុំអន្តរាគមន៍ផ្សេងៗមករាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌពាក់ព័ន្ធនឹងវិវាទកិច្ចការច្បាប់ និងតុលាការរួចបញ្ជូនមកមេធាវីរាជរដ្ឋាភិបាលសម្រាប់លើកយោបល់ជូនថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និងសម្រេច

-គ្រប់គ្រងកិច្ចការបណ្តឹងទាំងឡាយ ក្នុងក្របខ័ណ្ឌបណ្តឹងដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់រាជរដ្ឋាភិបាល

-តាមដាន ពិនិត្យ និងស្រាវជ្រាវឯកសារពាក់ពន្ធ័នឹងពាក្យបណ្តឹងទាំងឡាយ ដែលថ្នាក់ដឹកនាំទីស្តីការ-គណៈរដ្ឋមន្ត្រី និងប្រមុខរាជរដ្ឋាភិបាលប្រគល់ឱ្យ

-ទទួលភារកិច្ចផ្សេងៗទៀតដែលមេធាវីរាជរដ្ឋាភិបាលប្រគល់ឱ្យ ។

**ប្រការ ៤ :** មេធាវីរាជរដ្ឋាភិបាល មានសិទ្ធិលើកសំណើជូនឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ពិនិត្យ និងសម្រេចលើមន្ត្រីរាជការនៅលេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាល ។

**ប្រការ ៥ :** រាល់ការចំណាយរបស់លេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាល ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៦ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧ :** អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធានគ្រប់នាយកដ្ឋាន និងអង្គភាពចំណុះទីស្តីគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ និងមេធាវីរាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល**

- ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- សាលាខេត្ត ក្រុង
- ដូចប្រការ ៧
- ឯកសារ កាលប្បវត្តិ